# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Aug-2014, 14:05
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សំណើរបស់ លោក ខៀវ សំផន
# សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្ដើមការជំនុំជម្រះសំណុំរឿង ០០២/០២ និង សុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្ដារា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

កញ្ញា អ៊ួច ស្រីផាត

កញ្ញា សេង លីណា

កញ្ញា Cécile ROUBEIX

លោក Clément BOSSIS

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានបើកសវនាការបឋមលើសំណុំរឿង ០០២/០២ ( E1/240.1)។

២. នៅពេលនោះ លោកប្រធានអង្គជំនុំជម្រះ បានបង្ហាញពីបំណងរបស់ខ្លួនចង់ឲ្យការជំនុំជម្រះនៅវគ្គទីពីរនេះ ចាប់ផ្តើមឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ដែលនឹងអាចធ្វើឡើងចាប់ពីខែ កញ្ញា ឆ្នាំ ២០១៤ នេះតទៅ។

៣. សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងក្រុមមេធាវីការពារក្តី លោក នួន ជា ផង ហាក់ដូចជាបានសម្តែងក្តីរីករាយចំពោះកាលវិភាគមួយនេះ ហើយពួកគេបានទាំងផ្តល់ការគាំទ្រដោយផ្ទាល់មាត់ទៀតផង។

៤. ចំណែកក្រុមមេធាវីការពារក្តី លោក ខៀវ សំផន (“ក្រុមមេធាវីការពារក្តី”) វិញ នៅក្នុងសវនាការថ្ងៃទី ៣០ ខែ កក្កដា នេះដែរ ខ្លួនបានសម្តែងការព្រួយបារម្ភពីរបៀបនៃការប្រព្រឹត្តទៅនៃការជំនុំជម្រះវគ្គទីពីរក្នុងសំណុំរឿង ០០២ ប្រសិនបើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ នាំទៅដល់ការធ្វើសេចក្តីសន្និដ្ឋានផ្សេងៗដែលរងការជំទាស់ដោយភាគីទាំងអស់ និងជាពិសេសដោយក្រុមមេធាវីការពារក្តី។

៥. ជំហរនេះធ្លាប់បានបង្កើតឲ្យមានជាកិច្ចពិភាក្សាមួយកាលពីខែ កុម្ភៈ ឆ្នាំ ២០១៤ នៅពេលដែលក្រុមមេធាវីការពារក្តីជំទាស់មិនឲ្យបើកការជំនុំជម្រះក្នុងវគ្គទីពីរក្នុងសំណុំរឿង ០០២ ដរាបណាអង្គជំនុំជម្រះតុលាការកំពូល មិនទាន់បានចេញសាលដីការស្ថាពរលើសំណុំរឿង ០០២/០១ (E301/5/5)។ សំណើសុំព្យួរពេលលើកទីមួយនេះ ត្រូវបានបដិសេធដោយដោយអង្គជំនុំជម្រះតាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ (E301/5/5/1)។

៦. ចាប់ពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ សាលក្រមក្នុងសំណុំរឿង ០០២/០១ (E313) ត្រូវបានប្រកាស ហើយក្រុមមេធាវីការពារក្តីបានជួបប្រទះនូវក្តីកង្វល់នានា ដែលពេលខ្លះកង្វល់ទាំងនោះអាចចាត់ទុកជាកង្វល់ “ដ៏ជ្រាលជ្រៅ”។ ជាក់ស្តែង វាច្បាស់ណាស់ថា នៅក្នុងសេចក្តី

សម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានឈានចេញហួសពីវិសាលភាពនៃការជំនុំជម្រះ ដូចបានកំណត់នៅក្នុងសេចក្តីសម្រេចគោលរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងបញ្ហានេះ។ ស្ថានភាពនេះបានស្តែងឲ្យឃើញកាន់តែច្បាស់ថែមទៀត នោះគឺ កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ (E301/9/1/1/3) ហើយដែលតាមរយៈសេចក្តីសម្រេចនោះ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលទឡ្ហីករណ៍ដែលអង្គជម្រះសាលាដំបូងបានប្រើប្រាស់ដើម្បីបញ្ចៀសជាមុន នូវរាល់ការស្តីបន្ទោសទាំងឡាយមកលើខ្លួន។

៧. ដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ និងសាលក្រមរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ គឺជាអង្គហេតុថ្មីៗ ដែលជាមូលហេតុនាំឲ្យមានការធ្វើសំណើថ្មីមួយនៅពេលនេះ ដើម្បីស្នើសុំកុំទាន់ឲ្យចាប់ផ្តើមការជំនុំជម្រះវគ្គទីពីរក្នុងសំណុំរឿង ០០២ ដរាបណាអង្គជំនុំជម្រះតុលាការកំពូល មិនទាន់សម្រេចជាស្ថាពរលើបណ្តឹងសាទុក្ខទាំងឡាយធ្វើឡើងប្រឆាំងនឹងសាលក្រមមួយនេះ។

៨. ក្រុមមេធាវីការពារក្តី ស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាយល់ស្របថា៖ ចំណុចទាំងឡាយដែលត្រូវបានលើកឡើងមកនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់តាមផ្លូវគតិយុត្ត។ ចំណុចទាំងនេះត្រូវបានលើកឡើងដោយផ្អែកលើការសង្កេតជាក់ស្តែង។ ដំណោះស្រាយដែលអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវប្រកាន់យកចំពោះការរិះគន់ទាំងអស់នេះ អាចនឹងនាំឲ្យមានផលប៉ះពាល់ដល់សំណុំរឿង ០០២/០២។ ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ និងផលប្រយោជន៍យុត្តិធម៌ គេគួររង់ចាំលទ្ធផលលើបណ្តឹងសាទុក្ខជាមុនសិន មុននឹងចាប់ផ្តើមការជំនុំជម្រះវគ្គទីពីរនេះ។

៩. ជាការចាប់ផ្តើមក្នុងការពិចារណារបស់ខ្លួន ក្រុមមេធាវីការពារក្តីសូមលើកយកនូវសម្រង់មួយចេញពីសេចក្តីសម្រេចថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងឧទ្ធរណ៍លើកទីពីររបស់ក្រុមមេធាវីការពារក្តី ទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធី និងការកំណត់វិសាលភាពសំណុំរឿង ០០២/០២ (E301/9/1/1/3 កថាខណ្ឌ ៩៨) ដែលក្រុមមេធាវីការពារក្តីយល់ឃើញថាមានភាពពាក់ព័ន្ធជាពិសេសលើចំណុចនេះ៖

*“នៅក្នុងស្ថានការណ៍ដែលសាលក្រមក្នុងសំណុំរឿង ០០២/០១ បានឈានដល់ការសម្រេច*

*ដាក់ពិរុទ្ធភាពមួយ នោះនឹងមានហានិភ័យលើបញ្ហាជាន់គ្នានៃការយល់ឃើញ ដែលកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងការជំនុំជម្រះបន្តបន្ទាប់។ តាមន័យអរូបី នឹងមានការកើនឡើងនូវហានិភ័យជាមួយនឹងបញ្ហានៃការបំបែកសំណុំរឿងជាច្រើនផ្នែកបន្ថែមទៀត ប៉ុន្តែបញ្ហានៅតែមានសុពលភាពសម្រាប់សំណុំរឿង ០០២/០២ ដោយមិនជាប់ពាក់ព័ន្ធនឹងការបំបែកឡើយ។ ដោយមានការសម្រេចបដិសេធលើសំណើសុំការរង់ចាំនូវការបញ្ចប់នៃសំណុំរឿង ០០២/០១ និងក្នុងពេលតែមួយ ការបដិសេធក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ក្នុងអង្គជំនុំជម្រះសាលាដំបូង ដែលមួយក្នុងចំណោមនៃការស្នើឡើងទាំងពីរនេះ នឹងអាចជួយសម្រាលដល់ក្តីកង្វល់នេះបាននោះ អង្គជំនុំជម្រះតុលាការកំពូល អាចត្រឹមតែធ្វើការសន្មតថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនធ្វើឱ្យការយល់ឃើញក្នុងសំណុំរឿង ០០២/០១ ទៅបង្ហាញជាការសន្មតនូវការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើសហជនជាប់ចោទ ទាក់ទងនឹងបទចោទដែលត្រូវជំនុំជម្រះក្នុងរឿងក្តីបន្តបន្ទាប់នោះទេ។ ទោះបីជាយ៉ាងណាក្តី ក្នុងដំណាក់កាលនេះ ដោយសារពុំទាន់មានសាលក្រមនៅក្នុងដៃ បញ្ហានៃភាពលំអៀង ពុំទាន់កើតឡើងដែលជាការប៉ះពាល់ដល់សិទ្ធិជាក់ច្បាស់នៅឡើយទេ"*។

១០. យើងនឹងយល់បញ្ហាទាំងអស់នេះ ព្រោះថា សារណានេះយល់ស្របថាឮសនកម្មលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល មានភាពជាក់ច្បាស់ចាប់ពីពេលនេះទៅ ហើយក្នុងរយៈពេលនៃការរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើផលវិបាកផ្សេងៗនោះ យើងគួរតែទាញចេញនូវស្ថានភាពមួយ ពោលគឺការជំនុំជម្រះក្នុងវគ្គទីពីរត្រូវតែស្ថិតក្នុងការរង់ចាំសិន។

## **<u>វិញ្ញកពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ ដែលកំណត់ដោយអង្គជំនុំជម្រះ</u>**

១១. ដើម្បីយល់ឱ្យបានច្បាស់ពីទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី យើងត្រូវកំណត់ជាបឋមពីអត្ថសញ្ញាណនៃសេចក្តីសម្រេច ដែលកំណត់ពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ ជាមុនសិន។ បញ្ហាបែបនេះអាចទំនងគួរឱ្យអស់សំណើច ប៉ុន្តែក្នុងក្របខណ្ឌនៃដំណើរការនីតិវិធីបែបកួនកាត់នាពេលបច្ចុប្បន្ននេះ ការចេញសេចក្តីសម្រេចបន្តបន្ទាប់គ្នា និងមានចំនួនច្រើនបែបនេះ ធ្វើឱ្យបញ្ហានេះមានភាពពាក់ព័ន្ធវិញ។

១២. ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានរំលឹកនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ (E301/9/1/1/3 កថាខណ្ឌ ១៨) ៖*"ក៏ប៉ុន្តែ នៅក្នុងបរិបទនៃ អវតក ការកម្រិតនៃអំពើឧក្រិដ្ឋ ត្រូវបានធ្វើឡើងទៅតាមការចោទប្រកាន់នៃអង្គហេតុ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាជាងតាមការកំណត់ប្រភេទនៃបទល្មើស ដែលមិនមានលក្ខណៈចាប់បង្ខំតាមផ្លូវច្បាប់"* ។

១៣. ដោយហេតុថា សំណុំរឿងវគ្គទីមួយ ត្រូវបានកំណត់ដោយការបំបែកកិច្ចដំណើរការនីតិវិធីលើដីកាបញ្ជូនរឿងទៅជម្រះ ហេតុនេះ សេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ (E284) ដែលបានចូលជាស្ថាពរជាមួយនឹងសេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ (E284/4/7) គឺជាអ្នកកំណត់វិសាលភាពនៃសំណុំរឿងនេះ។

១៤. វិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលកំណត់ថា ឯកសារដែលមានតម្លៃលើការបំបែកកិច្ចដំណើរការនីតិវិធីនោះ គឺមានតែដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនោះទេ៖

> *"នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬ ច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប"* ។

១៥. យើងសូមរំឭកដែរថា នៅពេលធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលបានធ្វើឡើងនៅក្នុងដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន គឺមានតែដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនានា ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង និងឧបសម្ព័ន្ធទាំងឡាយដែលពាក់ព័ន្ធនោះទេ ដែលត្រូវបានផ្តោតជាសំខាន់ តែពុំមែនឯកសារគតិយុត្តិណាមួយផ្សេងទៀតនោះឡើយ។

១៦. នៅក្នុង**ផ្នែកសេចក្ដីសម្រេច** នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ (E284) អង្គជំនុំជម្រះបានបញ្ជាក់ថា៖

> "***សម្រេចថា***វិសាលភាពនៃមូលដ្ឋានបទល្មើសក្នុងសំណុំរឿង *០០២/០១* មាននៅក្នុងផ្នែកនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការផ្លាស់ទីលំនៅដោយបង្ខំ ដំណាក់កាល ទី ១ និងទី ២ ការសម្លាប់មនុស្សដែលត្រូវបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ដែលកើតមានភ្លាមៗក្រោយថ្ងៃជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលពាក់ព័ន្ធដទៃទៀត គឺជាបណ្ដាកថាខណ្ឌទាំងឡាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង *០០២* ដែលបានបញ្ជូនទៅភាគីកាលពីលើកមុន ក្នុងឯកសារ E124/7.3*"។

១៧. នៅក្នុងផ្នែកសេចក្ដីសម្រេចនោះដែរ អង្គជំនុំជម្រះបានបញ្ជាក់ថា៖

> "***ប្រកាសទៀតថា*** *ដើម្បីឲ្យមានភាពប្រាកដប្រជា អង្គជំនុំជម្រះមិនត្រូវទទួលយកការពង្រីកវិសាលភាពនៃការជំនុំជម្រះលើសំណុំរឿងលេខ ០០២/០១ ទៀតឡើយ ហើយអង្គជំនុំជម្រះក៏បាន****កត់សម្គាល់ថា*** *អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង បណ្ដឹងសាទុក្ខភ្លាមៗចំពោះសេចក្ដីសម្រេចនាពេលបច្ចុប្បន្ន ពុំបានផ្អាកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ*" ។

១៨. ផ្អែកតាមខ្លឹមសារនៃសេចក្ដីសម្រេចចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ នេះ ហើយដែលត្រូវបានចូលជាស្ថាពរតាមរយៈសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ (E284/4/7) គឺឯកសារ E124/7.3 ដែលជាអ្នកកំណត់ពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ និងជាឯកសារដែលបានជូនដំណឹង លោក ខៀវ សំផន ពីអង្គហេតុ និងការចោទប្រកាន់នានាប្រឆាំងនឹងរូបលោកនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៩. នៅក្នុងឯកសារ E124/7.3 កថាខណ្ឌទាំងឡាយដែលត្រូវបានជ្រើសរើសយក ដើម្បីកំណត់ពីវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ហើយដែលកថាខណ្ឌទាំងអស់នោះពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ មានជាប់ទាក់ទិននឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា (តែមិនពាក់ព័ន្ធនឹងគោលនយោបាយបង្កើតឡើងដោយបក្សកុម្មុយនីស្តឡើយ) ព្រមទាំងមានជាប់ទាក់ទងនឹងប្រវត្តិនៃគោលនយោបាយតែពីរគត់ ដែលជាកម្មវត្ថុនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ រួមមាន

នយោបាយជម្លៀសប្រជាជន និងនយោបាយទាក់ទិននឹងការចាត់វិធានការដាក់លាក់ប្រឆាំងនឹងអតីតអ្នកទទួលខុសត្រូវរបបសាធារណរដ្ឋខ្មែរ។

២០. ជាឧទាហរណ៍ ឯកសារ E124/7.3 នេះ ពុំបានជ្រើសរើសយកកថាខណ្ឌ ១៦៨ និង កថាខណ្ឌ ១៧០ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាកថាខណ្ឌតែពីរគត់ដែលត្រូវលើកយកមកពិចារណា ដោយសារកថាខណ្ឌនោះបានលើកឡើងថា *"សហករណ៍ និងការដ្ឋាននានា ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីមុនឆ្នាំ ១៩៧៥ ម្ល៉េះ ពោលគឺនៅដំណាក់កាលដំបូងៗនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាលើដែនដីមួយចំនួនរបស់ប្រទេស"* ឬក៏ *"បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយសមូហភាពលើផលិតផលកសិកម្ម ក្នុងអំឡុងឆ្នាំ ១៩៧០ និងបានបង្កើនការអនុវត្តនយោបាយនេះ ខណៈដែលបក្សកុម្មុយនីស្តកម្ពុជាបានពង្រឹងការកាន់កាប់របស់ខ្លួនលើទឹកដីទាំងមូលនៃប្រទេសកម្ពុជា"*។

២១. ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ឯកសារ E124/7.3 នេះ ពុំបានជ្រើសរើសយកកថាខណ្ឌ ១៨២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាកថាខណ្ឌតែមួយគត់ (ជាមួយនឹងកថាខណ្ឌ ១៩៤ ផងដែរ ដែលមិនត្រូវបានជ្រើសរើសយកដោយឯកសារ E124/7.3) ដែលត្រូវលើកយកមកពិភាក្សា ព្រោះថាគោលនយោបាយនេះបាន *"(...) វិវត្តទាំងមុន និងក្នុងអំឡុងពេលនៃរបបនោះ។ តាំងតែពីទសវត្សរ៍ឆ្នាំ ១៩៧០ មន្ទីរសន្តិសុខ និងទីពិឃាតមនុស្សត្រូវបានបង្កើតឡើងនៅតាម "តំបន់រំដោះ" និងត្រូវបានគេប្រើប្រាស់ដើម្បីកសាង និងសម្លាប់ខ្មាំង"*។

២២. ករណីដូចគ្នាក៏កើតមានសម្រាប់ការរៀបការដោយបង្ខំ៖ ឯកសារ E124/7.3 ពុំបានជ្រើសយកកថាខណ្ឌ ២១៦ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាកថាខណ្ឌតែមួយគត់ ដែលនិយាយឡើងវិញពីប្រវត្តិនៃការរៀបចំគោលនយោបាយមួយនេះ ដោយបានបញ្ជាក់ថា *"បក្សបានបង្ខំឱ្យសហព័ទ្ធរៀបការនឹងគ្នាតាំងពីមុនឆ្នាំ ១៩៧៥ នៅពេលខ្លួនកាន់កាប់លើតំបន់មួយចំនួននៅក្នុងទឹកដីប្រទេសកម្ពុជា (...)"*។

**<u>ការរំលោភលើវិសាលភាពនៃសំណុំរឿង ០០២/០១ និងការកំណត់ទុកជាមុននូវការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ លោក ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០២</u>**

២៣. យ៉ាងណាមិញ ទោះបីជាសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលក៏ដោយ យើងអាចចោទសួរថាតើគេឃើញមានអ្វីខ្លះនៅក្នុងសាលក្រមចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូង? ច្បាស់ណាស់ អ្វីដែលគេឃើញនោះ គឺអង្គហេតុនានាដែលពុំស្ថិតនៅក្នុងវិសាលភាពកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ ក្នុងសំណុំរឿង ០០២/០១។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ។

២៤. នៅក្នុងផ្នែកដែលមានចំណងជើងថា "***៣.៣.២ ការបង្កើតសហករណ៍ និងការផ្លាស់ការងារនៅមុនខែមេសា ឆ្នាំ ១៩៧៥***" ត្រង់កថាខណ្ឌ ១១៦ នៃសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា៖ "*អង្គជំនុំជម្រះជឿជាក់ថា នៅមុនឆ្នាំ ១៩៧៥ ពិតជាមានគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដើម្បីបង្កើតសហករណ៍ ដោយកំណត់ចេញនូវលក្ខខណ្ឌការងារដ៏លំបាកសម្រាប់សមាជិកសហករណ៍ រួមទាំងអ្នកទាំងឡាយដែលត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំទៅទីនោះ*"។

២៥. នៅក្នុងផ្នែកដែលមានចំណងជើងថា "***៣.៣.៣ ការអប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង***" ត្រង់កថាខណ្ឌ ១១៧ នៃសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា៖ "*មានភស្តុតាងបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើត [**និងអនុវត្ត**] គោលនយោបាយមួយបន្ថែមទៀត គឺការអប់រំកែប្រែ "សមាសភាពមិនល្អ" និង "កម្ទេច" អ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាជាខ្មាំង*"។ បន្ទាប់មកទៀត ក្រោយពីបានបង្ហាញពីអត្ថិភាពនៃជំរំមួយចំនួននៅចន្លោះឆ្នាំ ១៩៧០ និង ១៩៧៥ កថាខណ្ឌ ១១៨ បានបន្ថែមថា៖ "*គោលនយោបាយកម្ទេចខ្មាំងបន្ត**អនុវត្ត**រហូតដល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាគោលនយោបាយនេះមានការវិវត្តប្រែប្រួលក្តី។ ចាប់តាំងពីឆ្នាំ ១៩៧០ តិញដែលរួមមាន សេ.អ៊ី.អា កា.ហ្សេ.បេ និងវៀតណាម ("យួន") ត្រូវបានគេចាត់ទុកថាជាខ្មាំងសំខាន់*"។

២៦. នៅក្នុងផ្នែកដែលមានចំណងជើងថា "***៣.៣.៥ ការរៀបការដោយបង្ខំ***" ត្រង់កថាខណ្ឌ ១២៨ នៃសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា៖ "*ដីកាដំណោះស្រាយ (*នៅទីនេះ គឺកំណត់សម្គាល់ជើងទំព័រលេខ ៣៧០ ដែលយោងទៅកថាខណ្ឌ ១១៤៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ*) លើកឡើងថា នៅមុនឆ្នាំ ១៩៧៥ និងនៅក្រោយឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំឲ្យមានការរៀបអាពាហ៍ពិពាហ៍ និងជំរុញឲ្យធ្វើការបង្កកំណើត ដើម្បីបង្កើនចំនួនប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*"។ ក្រោយមកបន្តិច នៅក្នុងកថាខណ្ឌ ១៣០ នៃសាលក្រម អង្គជំនុំជម្រះបានសន្និដ្ឋានថា "*ប៉ុន្តែ ភ័ស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រចិត្តនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍គឺជាគោលនយោបាយមួយរបស់បក្សកុម្មុយនីស្តកម្ពុជា*"។ ជាក់ស្តែង យើងសូមគូសបញ្ជាក់ថា កថាខណ្ឌ ១១៤៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលកំណត់សម្គាល់ជើងទំព័រលេខ ៣៧០ យោងទៅនោះ ពុំមែនជាកថាខណ្ឌមួយក្នុងចំណោមកថាខណ្ឌទាំងឡាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានជ្រើសរើសដោយឯកសារ E124/7.3 នោះទេ។

២៧. តាមរយៈឧទាហរណ៍ទាំងបីខាងលើ យើងឃើញថា នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនត្រឹមតែបានឃ្លាតចេញយ៉ាងច្បាស់ ពីវិសាលភាពផ្លូវការនៃការជំនុំជម្រះវគ្គទីមួយ ដែលខ្លួនបានកំណត់នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីចុងក្រោយរបស់ខ្លួន ហើយដែលសេចក្តីសម្រេចនេះ ត្រូវបានទទួលស្គាល់នៅដំណាក់កាលប្តឹងឧទ្ធរណ៍នោះទេ ប៉ុន្តែអង្គជំនុំជម្រះ ថែមទាំងពុំបានគោរពនូវភាពខុសគ្នារវាងពាក្យ "ការបង្កើត" និង "ការអនុវត្ត" ដែលពាក្យទាំងពីរនេះបានជួយដល់អង្គជំនុំជម្រះមួយរយៈ នៅពេលដែលខ្លួនព្យាយាមធ្វើយុត្តិកម្មលើកំហុសទាំងឡាយដែលក្រុមមេធាវីការពារក្តី បានប្តឹងរួចមកហើយ។

២៨. យើងអាចកត់សម្គាល់បានដែរថា កថាខណ្ឌទាំងឡាយដែលទើបត្រូវបានរៀបរាប់ខាងដើម គឺមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ ត្រង់ផ្នែកមួយដែលមានចំណងជើងថា "**បរិបទប្រវត្តិសាស្ត្រ**" ហើយដែលភ្ជាប់នឹងចំណងជើងនេះ មានកំណត់សម្គាល់ជើងទំព័រមួយ ដែលនៅខាងក្រោមនោះ យើងអាចអានបាននូវការបញ្ជាក់យ៉ាងច្បាស់ ដូចខាងក្រោមនេះ៖

> "*ភ័ស្តុតាងដែលត្រូវបានពិភាក្សានៅក្នុងផ្នែកនេះត្រូវបានផ្តល់ក្នុងគោលបំណងបង្ហាញអំពីបរិបទប្រវត្តិសាស្ត្រ និងអង្គហេតុនៃហេតុការណ៍ទាំងឡាយដែលស្ថិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក។ **ភ័ស្តុតាងបែបនេះអាចរួមមាន៖ ការបញ្ជាក់បំភ្លឺទៅលើ***

*បរិបទជាក់លាក់ណាមួយ* ***ដោយបង្ហាញតាមរយៈការទាញសេចក្តីសន្និដ្ឋានពីធាតុផ្សំនៃអំពើឧក្រិដ្ឋ****នៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ឬដោយបង្ហាញអំពីបែបផែននៃអំពើដោយចេតនាណាមួយ*"។

២៩. ការទទួលស្គាល់យ៉ាងប្រត្យក្ស នូវការណ៍ដែលអង្គជំនុំជម្រះបានរកឃើញពិរុទ្ធភាពរបស់ លោក ខៀវ សំផន ដោយផ្អែកតាមធាតុផ្សំនានាដែលមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះ (វិសាលភាពដែលអង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានកំណត់ និងកំហិត តាមរយៈសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដោយបានយោងយ៉ាងច្បាស់ទៅលើឯកសារឧបសម្ព័ន្ធ E124/7.3) បានក្លាយជាកម្មវត្ថុនៃការព្យាយាមការពារខ្លួនជាមុន ដូចមានចែងនៅក្នុងកថាខណ្ឌ ៤៦៖

> "*នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានទទួលយកភស្តុតាងនៃអង្គហេតុ****ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង00២/0១*** *នៅពេលមានការបង្ហាញថាវាមានភាពពាក់ព័ន្ធជាអាទិ៍ ទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ បរិបទធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះ*"។

៣០. ការអះអាងបែបនេះ គឺពិតជាខុស ព្រោះថា ការយោងទៅលើ"*គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ*" ប្រាកដជានឹងនាំអ្នកអានមានសុទ្ធចិត្ត គិតទៅដល់គោលនយោបាយតែពីរគត់ ដែលអង្គជំនុំជម្រះបានជ្រើសរើសយក និងបានសម្រេចថាជាធាតុផ្សំនៃវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង 00២។

៣១. ការអះអាងនេះ ក៏ពិតជានឹងមិនអាចត្រូវបានបកស្រាយតាមរយៈទឡ្ហីករណ៍គួរឱ្យស្រឡាំងកាំង ដូចដែលមានពីខាងដើមនោះទេ (ស្ថិតក្នុងកថាខណ្ឌ ៤៦ ដដែល) ហើយដែលនៅក្នុងទឡ្ហីករណ៍នោះមានការគាំទ្រតាមរយៈកំណត់សម្គាល់ជើងទំព័រលេខ ១២៣ ថា ពេលខ្លះ អង្គជំនុំជម្រះទំនងជាបានទទួលយកនូវធាតុផ្សំមួយចំនួនដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង 00២ ទាំងមូលក្រោមលេសថា ធាតុផ្សំទាំងនោះមានភាពពាក់ព័ន្ធ។ ដូច្នេះ ការអនុវត្តបែបនេះ ក៏ទំនងជានឹងអាចបង្ហាញពីហេតុផលសមស្របផងដែរ ក្នុងករណីដែលអង្គជំនុំជម្រះ អាចនឹងទទួលយកធាតុផ្សំផ្សេងៗដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង 00២/0១ ប៉ុន្តែវាត្រូវបានចាត់ទុកក្នុង

វិសាលភាពនៃសំណុំរឿង ០០២ ទាំងមូលតែម្តង។ ទង្វើករណ៍នេះ មិនត្រឹមតែមិនអាចយល់បានទេ ប៉ុន្តែសេចក្តីសម្រេចដែលកំណត់សម្គាល់ជើងទំព័រលេខ ១២៣ យោងទៅលើនោះ គឺមានការពាក់ព័ន្ធនឹងអនុស្សរណៈមួយ ហើយដែលតាមរយៈអនុស្សរណៈនោះ អង្គជំនុំជម្រះបានបដិសេធទទួលយកធាតុផ្សំនានាដែលពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២ ទាំងមូល។

៣២. ដូចគ្នានេះដែរ គេអាចកត់សម្គាល់បានថា នៅពេលដែលគេត្រូវធ្វើការពិនិត្យលើក្រុមមនុស្សជាក់លាក់ផ្សេងៗ ក្រៅពីក្រុមអតីតអ្នកទទួលខុសត្រូវរបបសាធារណរដ្ឋខ្មែរ (ជនជាតិចាមពុទ្ធសាសនិកជន និងជនជាតិវៀតណាម) អង្គជំនុំជម្រះបានសម្រេចគួរឲ្យភ្ញាក់ផ្អើល ក្នុងការមិនពិនិត្យលើការ “បង្កើត” ឬ “ប្រវត្តិ” ឬ “អត្ថិភាព” នៃក្រុមនុស្សទាំងនោះ ដើម្បីឲ្យអ្នកអានទៅមើល (សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ៣៤២) ការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះលើការបំបែកកិច្ចដំណើរការនីតិវិធី ក៏ដូចជាទៅមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយនឹងសេចក្តីសម្រេចនោះ។ ការបត់បែនយ៉ាងលឿនក្នុងការគោរពសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ធ្វើឲ្យក្រុមមេធាវីការពារក្តី លោក ខៀវ សំផន មានការងឿងឆ្ងល់ ហើយមេធាវីការពារក្តីមានការសោកស្តាយ ដែលអង្គជំនុំជម្រះមិនបានអនុវត្តរបៀបដូចគ្នានេះចំពោះអង្គហេតុទាំងអស់ ដែលមិនស្ថិតនៅក្នុងវិសាលភាពកំណត់ដោយសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធី និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

៣៣. អស់រយៈពេលជាច្រើនខែមកហើយដែលក្រុមមេធាវីការពារក្តី បានតវ៉ាប្រឆាំងនឹងការអនុវត្តដែលចេះតែលេចចេញមកបន្តិចម្តងៗ និងជាការអនុវត្តមួយដែលក្រុមមេធាវីការពារក្តីបានទាយទុកជាមុន ហើយដែលនៅពេលនេះ វាបានបង្ហាញខ្លួនឲ្យឃើញច្បាស់ក្រឡែតនៅក្នុងសាលក្រម ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ នៅក្នុងសាលក្រមនោះ វាច្បាស់ណាស់ថា អង្គជំនុំជម្រះបានអនុវត្តហួសពីវិសាលភាពនៃបណ្តឹងដែលខ្លួនទទួលបាន។ សំណួរដែលចង់ដឹងថា តើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាច ឬមិនអាចបំបែកបាននោះ គឺពុំមានពាក់ព័ន្ធផ្ទាល់នឹងលោក ខៀវ សំផន ឡើយ។ ហេតុផលនោះគឺថា បញ្ហាមិនមែនស្ថិតនៅត្រង់ការចង់ដឹងថា តើអង្គជំនុំជម្រះនឹងអាចកាត់សេចក្តី លោក ខៀវ សំផន បានដោយបែបណានោះទេ ប៉ុន្តែបញ្ហាពិតគឺវានៅត្រង់ថា តើអង្គជំនុំជម្រះបានកាត់សេចក្តី លោក ខៀវ សំផន បែបណាទៅវិញនោះទេ។ របៀបដែលអង្គជំនុំជម្រះវិនិច្ឆ័យទោស លោក ខៀវ សំផន អាចឲ្យគេជំទាស់បាន ព្រោះថា អង្គជំនុំជម្រះ

បានគិតជាជាបឋមលើការពិចារណាទាញចេញពីការអនុវត្តជាក់ស្ដែង (ទៅមុខឲ្យបានលឿនតាមដែលអាចធ្វើទៅបាន តម្រូវចិត្តបណ្ដាប្រទេសម្ចាស់ជំនួយ និងដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដល់ដល់ពួកគេនូវសាលក្រមផ្ដន្ទាទោសមួយទាំងមូល មុននឹងជនជាប់ចោទស្លាប់ ឈានទៅដល់សេចក្ដីសម្រេចមួយ ទោះបីជាសេចក្ដីសម្រេចនោះអាចត្រូវរងការជំទាស់ក៏ដោយ ក្នុងខណៈដែល អ.វ.ត.ក នៅទទួលបានជំនួយហិរញ្ញវត្ថុ ហើយជនជាប់ចោទនៅកំពុងមានជីវិត) មុននឹងសម្រេចធ្វើការពិចារណាលើផ្នែកច្បាប់ជាមូលដ្ឋាន ដែលធ្លាប់ត្រូវបានរំឮកនៅក្នុងសំណើសុំមុនៗរួចមកហើយ។

៣៤. ធាតុផ្សំទាំងឡាយដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ប៉ុន្តែដែលធាតុផ្សំទាំងអស់នោះត្រូវបានអង្គជំនុំជម្រះយកមកធ្វើការពិចារណានៅក្នុងសាលក្រមរបស់ខ្លួន ពុំបានស្ថិតនៅដោយមានរបៀបក្នុងផ្នែកណាមួយនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រនោះទេ។ ធាតុផ្សំទាំងនោះ បានជួយយ៉ាងច្បាស់ក្នុងការកំណត់ពីឧក្រិដ្ឋកម្មដែលមានចែងក្នុងគោលការណ៍ច្បាប់ជាទូទៅ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងកំណត់ពីគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ ចំណុចនេះ មាននៅក្នុងកថាខណ្ឌទាំងឡាយដែលបានរៀបរាប់ពីខាងដើម និងនៅក្នុងសាលក្រម ត្រង់ផ្នែកដែលមានចំណងជើងថា "**១៤. សហឧក្រិដ្ឋកម្មរួម**" ផងដែរ។ ជាក់ស្ដែង កថាខណ្ឌ ៧២៥ បានបញ្ជាក់ថា៖"*គោលនយោបាយ និងផែនការទាំងឡាយសម្រាប់អនុវត្តគោលបំណងរួមនៅក្នុងអំឡុងរយៈពេលនេះ ត្រូវបានបង្កើតឡើងនៅមុនយុត្តាធិការពេលវេលារបស់តុលាការនេះទៅទៀត។ លើសពីនេះទៀត អ្នកចូលរួមសំខាន់ៗបំផុតបានចូលរួមនៅក្នុងគោលបំណងរួមនេះ តាំងពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកម្ល៉េះ។* ***ហេតុដូច្នេះ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីគោលគំនិតនៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់ត្រូវលើកឡើងអំពីការវិវត្តនៃគោលនយោបាយ និងផែនការនានា*** *ព្រមទាំងដំណាក់កាលផ្សេងៗដែលអ្នកចូលរួមទាំងនោះត្រូវបានគេស្គាល់*"។ បន្ទាប់មក គឺមានការវិភាគមួយយ៉ាងវែងលើគោលនយោបាយ**<u>ទាំងប្រាំ</u>**របស់បក្សកុម្មុយនីស្ដកម្ពុជា ប៉ុន្តែក្នុងនោះមានគោលនយោបាយចំនួនបី (ការបង្កើត និងការទទួលយកផលពីសហករណ៍ និងការដ្ឋានការងារ ការអប់រំកែប្រែសមាសភាពមិនល្អ និងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ការរៀបការដោយបង្ខំ) ដែលជាគោលនយោបាយដែលគេបានដឹងយ៉ាងច្បាស់ និងបើតាមផ្លូវច្បាប់វិញ គឺពុំស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ នោះឡើយ។

៣៥. ផលប៉ះពាល់នៃការរំលោភបំពាន ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងវិសាលភាពនៃការជំនុំជម្រះ ត្រូវបានអនុវត្តឡើង ដោយបានបង្កជាព្យសនកម្មដល់ជនជាប់ចោទទាំងពីររូប។ គេពុំអាចមិនគិតដល់ខ្លឹមសារចំនួនបួនទំព័រ ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលត្រូវបានសរសេរឡើង ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ទីរ ស-២១ ដោយ លោក នួន ជា (ទំព័រ ២២២ ដល់ទំព័រ ២២៥) នោះទេ ប៉ុន្តែទន្ទឹមគ្នានេះដែរ គេក៏ត្រូវរំឭកអំពីចរិតដែលមានលក្ខណៈទូទៅជាទីបំផុត និងសំអាងដោយបើកចំហលើគោលនយោបាយទាំងប្រាំ ដែលជាចំណុចនាំមុខ នៅក្នុងផ្នែកដែលមានចំណងជើងថា "**១៦. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន**" ក្នុងសាលក្រមរបស់អង្គជំនុំជម្រះ។ ទោះបីជាមានការប្រុងប្រយ័ត្នខ្លះៗក្នុងការសរសេរ និងការប្រកាសប្រាប់ពីចេតនាល្អៗក៏ដោយ ហើយដូចដែលអ្វីដែលអង្គជំនុំជម្រះបានធ្វើនៅក្នុងផ្នែកទាំងឡាយនៃសាលក្រម ដែលត្រូវបានរៀបរាប់ពីខាងដើមហើយក៏ដោយ វាពិតណាស់ដែលផ្នែកនេះមិនបានផ្អែកលើមូលដ្ឋាននៃការវិភាគមួយពាក់ព័ន្ធតែទៅលើគោលនយោបាយទាំងពីរ ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងវគ្គទីមួយក្នុងសំណុំរឿង ០០២ នោះទេ។ ផ្ទុយទៅវិញ ផ្នែកនេះបានផ្អែកលើការវិភាគមួយរួមលើចលនាខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈប្រវត្តិសាស្ត្រ ការបង្កើត និងការអនុវត្តនូវរាល់គោលនយោបាយទាំងឡាយ ដែលត្រូវបានចោទប្រកាន់មកលើរូប លោក ខៀវ សំផន តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៣៦. តាមគោលការណ៍ច្បាប់ ពុំមានការពិចារណាណាមួយទាញចេញពីការអនុវត្ត អាចត្រូវបានយកមកសំអាងថា គេកាត់ទោសមនុស្សម្នាក់ ដោយប្រើប្រាស់ធាតុផ្សំក្រៅសំណុំរឿងរបស់បុគ្គលនោះទេ ហើយក៏ពុំមានច្បាប់ណាមួយដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក អនុញ្ញាតឱ្យតុលាការមួយនេះប្រើប្រាស់ធាតុផ្សំក្រៅសំណុំរឿង ដើម្បីសម្រេចពីពិរុទ្ធភាពជនជាប់ចោទណាម្នាក់នោះទេ បើទោះបីជាជនជាប់ចោទរូបនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរខ្លាំងយ៉ាងណាក៏ដោយ។

៣៧. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី ដែលសុំឱ្យមានសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមួយថ្មី។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា ការបំបែកកិច្ចដំណើរការនីតិវិធី "*មានផលវិបាកផ្នែកនីតិវិធី បង្កើតឱ្យមានការជំនុំជម្រះដាច់ដោយឡែក និងខុសៗគ្នា*" (E301/9/1/1/3, កថាខណ្ឌ ៧០)។ ហេតុដូចនេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចធ្វើមោឃភាពលើទ្រឹស្តីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលយល់ឃើញថា

សំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ គ្រាន់តែជាដំណាក់កាលផ្ទៃក្នុង និងបន្តបន្ទាប់គ្នានៃសំណុំរឿង ០០២ ទាំងមូលតែមួយ។

៣៨. ចាប់តាំងពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ មក អង្គជំនុំជម្រះលែងអាចអះអាងបានទៀតហើយថា ការបញ្ចូលសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២ ទាំងមូល ទំនងជាអាចលុបលាងនូវកំហុសរបស់ខ្លួន ដែលបង្កមកពីការបំបែកកិច្ចដំណើរការនីតិវិធីដ៏សែនលំបាកមួយ ឬថែមទាំងមិនអាចទៅរួចបានទៀតផង។

៣៩. ចាប់ពីពេលនេះទៅ វាពិតច្បាស់ណាស់ និងមិនអាចប្រកែកបាន ដែលថា គឺមានតែសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ (យោងទៅឯកសារ E124/7.3) ដែលបានក្លាយជាសេចក្តីសម្រេចស្ថាពរ តាមរយៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ នោះទេ ដែលជាមូលដ្ឋានកំណត់ពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២ និងជាសេចក្តីសម្រេចដែលបានកំណត់យ៉ាងច្បាស់ពីធាតុផ្សំទាំងឡាយដែលអង្គជំនុំជម្រះអាចយកមកធ្វើការពិចារណា ដើម្បីផ្តន្ទាទោស លោក ខៀវ សំផន។ ដោយប្រើប្រាស់ធាតុផ្សំនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីសម្រេចលើការកំណត់បទល្មើសសហឧក្រិដ្ឋកម្មរួម ការកំណត់បទចោទពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ លោក ខៀវ សំផន អង្គជំនុំជម្រះបានឈានហួសចេញពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយក្នុងសំណុំរឿង ០០២។

៤០. ការកត់សម្គាល់នេះ មិនមែនកើតចេញមកតែពីការអានសាលក្រមទាំងមូល ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ នោះទេ ប៉ុន្តែ អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ ក៏បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា បានអនុវត្តបែបនេះ នៅក្នុងផ្នែកមួយចំនួននៃសាលក្រម ដែលបានរៀបរាប់ពីខាងលើផងដែរ។

៤១. អង្គជំនុំជម្រះមិនអាចអះអាងឲ្យបានប្រាកដប្រជាទាល់តែសោះថា ខ្លួនមិនដឹងថាអង្គហេតុរងការជំទាស់ ប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ សិទ្ធិត្រូវបានគេជូនដំណឹងអំពីអង្គហេតុដែលខ្លួនត្រូវជំនុំជម្រះ និងសិទ្ធិអាចត្រៀមលក្ខណៈការពារខ្លួន...។

៤២. លើសពីនេះទៅទៀត ដោយសារបានសម្រេចសេចក្តីទុកជាមុនលើអង្គហេតុនៅក្រៅបណ្តឹងទទួលបាន អង្គជំនុំជម្រះបានរំលោភបំពានលើគោលការណ៍សច្ចធានិរទោសរបស់លោក ខៀវ សំផន ក៏ដូចជាបានរំលោភបំពានលើសិទ្ធិទទួលបានការកាត់សេចក្តីដោយតុលាការមិនលំអៀង។

៤៣. ក្នុងលក្ខខណ្ឌទាំងនេះ ដើម្បីឲ្យសមហេតុផល អង្គជំនុំជម្រះត្រូវយល់ព្រមរង់ចាំសេចក្តីសម្រេចរបស់តុលាការកំពូលលើស្ថានភាពនេះជាមុនសិន មុននឹងចាប់ផ្តើមសវនាការវគ្គពីរ ក្នុងសំណុំរឿង ០០២។

៤៤. ក្នុងករណីដែលអង្គជំនុំជម្រះបដិសេធសំណើមួយនេះ ដែលមានលក្ខណៈសមហេតុផលពេញលេញ និងសមាមាត្រទៅនឹងស្ថានភាពនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យជ្រើសតាំងក្រុមប្រឹក្សាជំនុំជម្រះមួយថ្មី ក្នុងពេលនេះតែម្តង។

**<u>ការផ្អាកសវនាការ និងការប្តឹងជំទាស់ គឺជាមធ្យោបាយតែមួយដើម្បីថែរក្សាសិទ្ធិទទួលបានជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ</u>**

៤៥. ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះមេត្តាទទួលស្គាល់ថា ការរំលោភបំពានដែលជាទំនួលខុសត្រូវរបស់ខ្លួន មានកម្រិតធ្ងន់ធ្ងរ ហើយមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើការសវនាការសំណុំរឿង ០០២/០២ និងទទួលស្គាល់ថាស្ថានភាពបែបនេះជាមូលហេតុគ្រប់គ្រាន់ ដើម្បីផ្អាកសវនាការសំណុំរឿង ០០២/០២ ជាបណ្តោះអាសន្នសិន។

៤៦. ទាក់ទងនឹងដំណោះស្រាយបណ្តោះអាសន្ន ឬជាស្ថាពរ ចំពោះស្ថានភាពនេះ ក្រុមមេធាវីការពារក្តីតែងតែបញ្ជាក់ថា ការផ្អាកសវនាការសំណុំរឿង ០០២/០២ ជាដំណោះស្រាយដែលខ្លួនពេញចិត្តជាងគេ។

៤៧. ដំណោះស្រាយនេះមានគុណប្រយោជន៍ ធ្វើឲ្យអង្គជំនុំជម្រះទទួលបានផលពីវិមតិសង្ស័យដែលខ្លួនមិនព្រមផ្តល់ជូនលោក ខៀវ សំផន។ មិនតែប៉ុណ្ណោះ វាក៏ឆ្លើយតបទៅនឹងការរិះគន់ជាទូទៅលើសាលក្រម ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ទាក់ទងនឹងការជាន់គ្នានៃប្រធានបទដែលកំណត់

ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ ដូចដែលបានរៀបរាប់ពីខាងលើនេះ មិនត្រឹមតែអង្គជំនុំជម្រះបានបំពានលើវិសាលភាពនៃសំណុំរឿង ដែលខ្លួនបានកំណត់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងក្នុងកថាខណ្ឌ ៨៥ នៃសេចក្តីសម្រេច ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ខាងលើនេះ ដោយមិនជាប់ពាក់ព័ន្ធនឹងការបំបែក បញ្ហាជាន់គ្នាលើប្រធានបទនេះចោទឡើងនៅពេលពិនិត្យលើប្រធានបទ បរិបទប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធទំនាក់ទំនងការងារ និងតួនាទី និងមុខងាររបស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះបានពិនិត្យសម្រេចរួចហើយក្នុងសាលក្រម ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។ នៅពេលដែលប្រធានបទទាំងនេះនាំឱ្យមានការកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ - ហើយដែលជាករណីជាក់ស្តែងនេះ - សេចក្តីសន្និដ្ឋានដែលអង្គជំនុំជម្រះបានធ្វើឡើងក្នុងសាលក្រម ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ នេះ មិនអាចយកមកអនុវត្តបាននៅក្នុងសំណុំរឿងវគ្គពីរនេះបានឡើយ ដរាបណាការជំនុំជម្រះសំណុំរឿងវគ្គមួយនេះមិនទាន់បានក្លាយជាស្ថាពរ។ ការកត់សម្គាល់បន្ថែមនេះក៏ទាមទារការរង់ចាំឱ្យមានសេចក្តីសម្រេចជាស្ថាពរមួយដែរ។

៤៨. ទោះជាយ៉ាងណាក៏ដោយ បើអង្គជំនុំជម្រះគ្រោងបដិសេធសំណើផ្អាកសវនាការដែលជាសំណើចម្បងនេះ ជាបន្ទាប់បន្សំ មេធាវីការពារនឹងដាក់បណ្តឹងជំទាស់លើចៅក្រមរបស់អង្គជំនុំជម្រះទាំងអស់ (ដោយរួមបញ្ចូលទាំងចៅក្រមបម្រុង លោកស្រី FENZ ផងដែរ ពីព្រោះគាត់បានចូលរួមជំនុំជម្រះជាច្រើនដងដែរ នៅក្នុងសវនាការសំណុំរឿង ០០២/០១ ហើយបានចូលរួមចេញសេចក្តីសម្រេចមួយចំនួនដែរ) ដើម្បីឱ្យសវនាការនៃសំណុំរឿង ០០២/០២ ដំណើរការទៅមុខប្រសិនបើត្រូវចាប់ផ្តើមភ្លាម ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះថ្មី ដែលមិនចេញសេចក្តីសម្រេចលើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចំពោះអង្គហេតុដែលសន្មតថាជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ និងសំណុំរឿងបន្តបន្ទាប់។

៤៩. គេនៅចាំថា នៅក្នុងសេចក្តីសម្រេចពីមុនរបស់ខ្លួនលើប្រធានបទដដែលនេះ កាលពីថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០១៤ (ឯកសារ E301/5/5/1) អង្គជំនុំជម្រះបានបដិសេធសំណើរបស់មេធាវីការពារក្តីដោយរំលឹកជាបឋមថា គោលការណ៍អាជ្ញាអស់ជំនុំមិនអាចលើកមកធ្វើមូលហេតុបានទេ ដរាបណាសាលក្រមស្ថាពរមិនទាន់ចេញ និងដោយរំលឹកទៀតថា តុលាការកំពូលប្រហែលជាចេញសាលដីកាលើបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ មុនពេលសវនាការនៃសំណុំរឿង ០០២/០២

ត្រូវបានបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (ប្រការនេះអាចធ្វើឱ្យក្រុមមេធាវីការពារក្តី ស្នើសុំឱ្យអង្គជំនុំជម្រះទាញយកផលវិបាកមានប្រយោជន៍ នៅក្នុងការជំនុំជម្រះវគ្គពីរ)។ អង្គជំនុំជម្រះក៏បានបន្ថែមផងដែរថា សាលក្រមនៃការជំនុំជម្រះវគ្គពីរ ក៏បើកផ្លូវប្តឹងសាទុក្ខដែរ។

៥០. នៅពេលនេះ សំអាងហេតុដែលចេះតែលើកការដោះស្រាយបញ្ហាទៅពេលក្រោយ លែងមានតម្លៃទៀតហើយ ក្នុងខណៈដែលការស្តីបន្ទោសនានាចំពោះចៅក្រមជំនុំជម្រះ បង្កឱ្យមានភាពមិនទុកចិត្តយ៉ាងខ្លាំងចំពោះសមត្ថភាពជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះ។ ជាក់ស្តែង ប្រសិនបើតុលាការកំពូលផ្តល់សុពលភាពដល់ការសង្កេតលើកឡើងដោយក្រុមមេធាវីការពារក្តីនាពេលនេះ នឹងមានការអះអាងថា អង្គជំនុំជម្រះបានកាត់ក្តីហួសបណ្តឹង ដោយកាត់សេចក្តីលើអង្គហេតុនៅក្រៅបណ្តឹងទទួលបាន។ ដូច្នេះ វាមិនសមស្របទេ ដែលលោក លោកស្រីចៅក្រម បន្តធ្វើជាចង់ដឹកនាំសវនាការលើអង្គហេតុ និងទំនួលខុសត្រូវព្រហ្មទណ្ឌ ដែលខ្លួនបានសម្រេចរួចស្រេចហើយនោះ។ វាក៏ជាការមិនសមស្របផងដែរ ក្នុងការផ្តល់ភារកិច្ចដល់លោក លោកស្រីចៅក្រម ដើម្បីជួសជុលស្ថានភាពមួយដែលខ្លួនបានបង្កើតឱ្យមានដោយចេតនានោះ។ ដូចដែលតុលាការកំពូលបានរំលឹកក្នុងសេចក្តីសម្រេចចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ (E301/9/1/1/3 កថាខណ្ឌ ៤៥) បញ្ហាភាពអាចបំបែកកិច្ចដំណើរការនីតិវិធី បានចោទឡើងចំពោះលោក លោកស្រីចៅក្រម ជាមុនស្រេច ខណៈដែលលោក លោកស្រីចៅក្រម បានគ្រោងបំបែកអំពើឧក្រិដ្ឋដែលមានលក្ខណៈស្មុគស្មាញ។ ការដោះស្រាយផលវិបាកអាក្រក់ដែលកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីនេះ ជាបញ្ហាបន្ទាន់បង្ខំ ហើយមិនអាចលើកទៅដោះស្រាយនៅពេលក្រោយ មិនចេះចប់មិនចេះហើយនោះទេ។

៥១. ការស្តីបន្ទោសចំពោះ លោក លោកស្រីចៅក្រម នៅពេលនេះ ហើយដែលតុលាការកំពូលនឹងមានឱកាសធ្វើសេចក្តីសម្រេច នៅពេលខ្លួនបានទទួលបណ្តឹងសាទុក្ខ គឺជាការអះអាងថា លោក លោកស្រីចៅក្រម បានសម្រេចលើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ លោក ខៀវ សំផន ស្រេចទៅហើយ ចំពោះអង្គហេតុនៅក្រៅចំណាត់ការរបស់អស់លោក លោកស្រី។ គួរតែរំលឹកផងដែរថា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ (E301/9/1/1/3 កថាខណ្ឌ ៨៣) តុលាការកំពូលយល់ឃើញថា ស្ថានភាពបែបនេះ អាចធ្វើឱ្យបាត់សច្ចធារណ៍នៃភាពមិនលំអៀងរបស់ចៅក្រមប្រកបដោយវិជ្ជាជីវៈ។

៥២. នៅទីបញ្ចប់ សូមរំលឹកផងដែរថា មូលហេតុមួយដែលជំរុញឲ្យអង្គជំនុំជម្រះសម្រេចបំបែកបទចោទប្រកាន់ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជម្រះ គឺស្ថានភាពសុខភាពផុយស្រួយរបស់ជនជាប់ចោទ។ សម្រាប់ពេលនេះ ស្ថានភាពសុខភាពផុយស្រួយនេះ បានត្រឹមតែយកមកប្រើប្រាស់ធ្វើជាសំអាងហេតុគាំទ្រសេចក្តីសម្រេចនានាដែលផ្តល់ផលអាក្រក់ដល់ លោក ខៀវ សំផន តែប៉ុណ្ណោះ។ ថ្ងៃនេះ លោក ខៀវ សំផន មានសិទ្ធិតម្រូវឲ្យរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលជាមុនសិន ក្នុងកាលទេសៈនេះ។

៥៣. ភាពធ្ងន់ធ្ងរ និងសារសំខាន់នៃបញ្ហាដែលលើកឡើងក្នុងសំណើនេះ ផ្តល់សំអាងហេតុថា ទោះជាក្នុងករណីណាក៏ដោយ ក៏ដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ ត្រូវតែផ្អាកសិន ដរាបណាមិនទាន់មានការសម្រេចពេញលេញលើសំណើទាំងប៉ុន្មាននេះ។

## ផ្អែកតាមសំអាងហេតុនេះ

៥៤. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះមេត្តា៖

**សម្រាប់សំណើចម្បង៖**

- **សម្រេច** និង**វិនិច្ឆ័យ** ថាសវនាការនៃសំណុំរឿង ០០២/០២ នឹងមិនចាប់ផ្តើមមុនពេលសាលក្រមនៃសំណុំរឿង០០២/០១ មិនទាន់ចេញជាស្ថាពរ។
- **សម្រេច** និង**វិនិច្ឆ័យ** ថាថាសវនាការនៃសំណុំរឿង ០០២/០២ នឹងមិនចាប់ផ្តើមមុនពេលដែលតុលាការកំពូលមិនទាន់បានសម្រេចលើសេចក្តីសម្រេចដែលរងបណ្តឹងសារទុក្ខទាំងអស់ក្នុងពេលជាមួយគ្នានឹងពេលចេញសាលក្រមលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/ ០១។

**សម្រាប់សំណើបន្ទាប់បន្សំ** ក្នុងករណីដែលអង្គជំនុំជម្រះបដិសេធសំណើចម្បង

- **កត់សម្គាល់**ជាផ្លូវការថា ក្រុមមេធាវីការពារក្តីស្នើសុំឲ្យជំនួស ចៅក្រម និល ណុន ចៅក្រម Sylvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូ ឧត្តរា ចៅក្រម Claudia FENZ ស្របតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ដោយក្រុមប្រឹក្សាជំនុំជម្រះថ្មីដែលនឹងមានបេសកកម្មកាត់សេចក្តីសំណុំរឿង ០០២/០២ ដោយមិនលំអៀង។

- **ផ្ដល់សំណើ**នេះទៅចៅក្រមបម្រុងទាំងអស់ដែលនឹងត្រូវបានជ្រើសតាំងឆាប់ៗខាងមុខ ស្របតាមអនុស្សារណៈ E314 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤។

**ក្នុងករណីណាក្ដី៖**

**ផ្អាក**ដំណើរការកិច្ចនីតិវិធីសំណុំរឿង ០០២/០២ ដរាបណាមិនទាន់មានសេចក្ដីសម្រេចពេញលេញលើសំណើនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |